ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ០១ បប

# បទបញ្ជា
## ស្តីពី
## ការពង្រឹងវិធានការប្រយុទ្ធប្រឆាំងគ្រឿងញៀន

ស្ថិតក្នុងស្ថានភាពដែលពិភពលោក និងតំបន់កំពុងតែប្រឈមទៅនឹងនិន្នាការកើនឡើងនូវការផលិត ការចរាចរណ៍ និងតម្រូវការទីផ្សារប្រើប្រាស់គ្រឿងញៀននោះ ព្រះរាជាណាចក្រកម្ពុជាក៏ជាប្រទេសមួយក្នុងចំណោមប្រទេសជាច្រើនទៀត ដែលទទួលរងគ្រោះដោយសារឥទ្ធិពលនៃបទឧក្រិដ្ឋគ្រឿងញៀន ហើយនៅដំណាក់កាលចុងក្រោយនេះ ការប្រើប្រាស់គ្រឿងញៀនបានរីករាលដាលគួរឱ្យព្រួយបារម្ភ ជាពិសេសក្នុងស្រទាប់យុវវ័យ ដោយបានបង្កឱ្យមានក្ដីកង្វល់ជារួមក្នុងសង្គមកម្ពុជា។

ឆ្លើយតបទៅនឹងសភាពការណ៍ខាងលើ និងក្នុងគោលដៅដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣ គោលនយោបាយភូមិឃុំមានសុវត្ថិភាពរបស់រាជរដ្ឋាភិបាល និងស្មារតីនៃអង្គសន្និបាតបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១៥ និងទិសដៅការងារឆ្នាំ២០១៦ សំដៅ បញ្ចៀសឱ្យបាននូវហានិភ័យដែលបណ្តាលមកពីគ្រឿងញៀន និងដើម្បីដោះស្រាយនូវការព្រួយបារម្ភជូនប្រជាពលរដ្ឋធានាបាននូវសុវត្ថិភាព សណ្តាប់ធ្នាប់ សន្តិសុខ និងការអភិវឌ្ឍសង្គម រាជរដ្ឋាភិបាលដាក់ចេញនូវបទបញ្ជាដូចខាងក្រោម ៖

១. អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវចាត់តាំងរៀបចំធ្វើសកម្មភាពឱ្យបានសកម្មខ្លាំងក្លាថែមទៀត ក្នុងការផ្សព្វផ្សាយអប់រំឱ្យមានការយល់ដឹងពីផលប៉ះពាល់ និងការចាកចេញពីឥទ្ធិពលគ្រោះថ្នាក់នៃគ្រឿងញៀនដល់ប្រជាពលរដ្ឋទូទៅ ពិសេសក្រុមគោលដៅងាយរងគ្រោះតាមគ្រប់រូបភាព និងលទ្ធភាពរៀងៗខ្លួន ។ ជាមួយនេះ ត្រូវជំរុញ លើកទឹកចិត្ត និងបំផុសឱ្យមានការចូលរួមពីគ្រប់មជ្ឈដ្ឋាននៃសង្គម ដៃគូពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ វិស័យឯកជន ចូលរួមសកម្មភាពឱ្យបានផុលផុស និងជាប្រចាំក្នុងការបញ្ជ្រាបខ្លឹមសារអប់រំពីបញ្ហាគ្រឿងញៀនទៅក្នុងកម្មវិធី និងសកម្មភាពផ្សេងៗរបស់ខ្លួន ។

២. អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងគណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ត្រូវចាត់ចែងរៀបចំពង្រឹង លើកកម្ពស់សមត្ថភាព ការគ្រប់គ្រង ការផ្តល់សេវា គុណភាពសេវាវេជ្ជសាស្ត្រ និងរៀបចំបង្កើត និងពង្រឹងយន្តការគាំទ្រដល់ដំណើរការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ និងសមាហរណកម្មទាំងសម្រាប់មណ្ឌលព្យាបាលបណ្តោះអាសន្ន និងការព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ ។ ជាមួយនេះ ក៏ត្រូវយកចិត្តទុកដាក់រៀបចំបង្កើតឱ្យ

មានការផ្តល់សេវាព្យាបាលពិរុទ្ធជន និងទណ្ឌិតដែលញៀនគ្រឿងញៀន ។ ក្រសួង អង្គភាព អាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ មន្ត្រីអនុវត្តច្បាប់ ត្រូវចូលរួម និងគាំទ្រក្នុងកិច្ចការទាំងនេះ ។

៣. ក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ពិសេសគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី-ខេត្ត ត្រូវពង្រឹងបន្ថែមទៀតនូវការអនុវត្តគោលនយោបាយ **"ភូមិ-ឃុំមានសុវត្ថិភាព"** និងផែនការប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន ដើម្បីបង្ការនូវអំពើចោរលួច ចោរប្លន់ និងគ្រប់គ្រងបាននូវមុខសញ្ញាជួញដូរ និងប្រើប្រាស់គ្រឿងញៀន ។ ជាមួយនេះ ត្រូវណែនាំដល់អង្គភាពអនុវត្តច្បាប់ឱ្យកសាងផែនការសកម្មភាពជាក់ស្តែង ដើម្បីពង្រឹងវិធានការបង្ការ និងវិធានការជំនាញ សំដៅធ្វើការទប់ស្កាត់ និងបង្ក្រាបនូវរាល់សកម្មភាពនៃការជ្រៀតចូល ការដឹកជញ្ជូនឆ្លងកាត់ ការផលិត ការដាំដុះ ការចម្រាញ់ ការស្តុកទុក ការជួញដូរ ការប្រើប្រាស់គ្រឿងញៀន និងការត្រួតពិនិត្យសារធាតុគីមីផ្សំ ឱ្យមានប្រសិទ្ធភាពខ្ពស់ទៅតាមតួនាទី ភារកិច្ច និងដែនសមត្ថកិច្ចរៀងៗខ្លួន ។ ទន្ទឹមនេះ ក៏ត្រូវធ្វើការលើកកម្ពស់សមត្ថភាពវិជ្ជាជីវៈ និងក្រមសីលធម៌ដល់មន្ត្រីអនុវត្តច្បាប់ ដើម្បីឱ្យការអនុវត្តច្បាប់មានប្រសិទ្ធភាព ។ ក្រសួងមហាផ្ទៃ ត្រូវពិនិត្យ កែសម្រួលឡើងវិញជាបន្ទាន់អំពីរបៀបរបបការងារ ក្នុងការឃុំគ្រងពិរុទ្ធជន-ទណ្ឌិតក្នុងមណ្ឌលអប់រំ-កែប្រែ ពិសេសកាត់ផ្តាច់ទំនាក់ទំនងរវាងមុខសញ្ញាខាងក្នុង និងខាងក្រៅមណ្ឌលអប់រំ-កែប្រែ ។ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវធ្វើការសម្របសម្រួលចំពោះកិច្ចការទាំងអស់នេះ និងត្រូវចូលរួមតាមដានក្នុងដំណើរការក្តីបទល្មើសគ្រឿងញៀន ដើម្បីប្រាកដថា ការផ្តន្ទាទោសសមស្របទៅនឹងទំហំនៃបទល្មើស និងមានប្រសិទ្ធភាពស្របតាមខ្លឹមសារនៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៤. អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងក្រសួងមហាផ្ទៃ ត្រូវពង្រឹងយន្តការ និងតួនាទីដឹកនាំទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីពង្រឹងការអនុវត្តទិសដៅការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនឆ្នាំ២០១៦ ដែលបានដាក់ចេញក្នុងសន្និបាតរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងផែនការជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀនទាំងមូលឱ្យ កាន់តែមានប្រសិទ្ធភាពថែមទៀត ។ ជាមួយនេះ គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី-ខេត្ត និងជាគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ត្រូវយកចិត្តទុកដាក់បំពេញមុខនាទីដឹកនាំរបស់ខ្លួនដោយការទទួលខុសត្រូវខ្ពស់តាមសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ **១៦៦ សសរ** ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ ដោយត្រូវបង្កើតយន្តការ និងរៀបចំឱ្យមានមន្ត្រីទទួលខុសត្រូវច្បាស់លាស់ជាបន្ទាន់ ដើម្បីដឹកនាំ តាមដាន ត្រួតពិនិត្យការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនតាមភូមិសាស្ត្រនីមួយៗ ។

៥. អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងក្រសួងមហាផ្ទៃ ត្រូវធ្វើការតាមដាន បូកសរុប វាយតម្លៃ និងធ្វើរបាយការណ៍ ពីលទ្ធផលជូនរាជរដ្ឋាភិបាល ដើម្បីមានមូលដ្ឋានដឹកនាំបន្តប្រកបដោយប្រសិទ្ធភាព ។

ទទួលបានបទបញ្ជានេះ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្រសួងមហាផ្ទៃ និងក្រសួង-ស្ថាប័ន មានសមត្ថកិច្ចពាក់ព័ន្ធទាំងអស់ត្រូវចាត់តាំងអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**